ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ៩ លេខ ៣៩ សប្តាហ៍ទី៤ ថ្ងៃទី ២៧ ខែឧសភា ឆ្នាំ ២០០៩

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

តម្លៃលក់

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់តម្លៃជាមុន)

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

ក

មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

១~ព្រះរាជក្រម

១៩-៥-២០០៩ -ព្រះរាជក្រម នស/រកម/០៥០៩/០០៤ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេសរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលរដ្ឋគូវ៉ែត ៣៤៤៣

១៩-៥-២០០៩ -ព្រះរាជក្រម នស/រកម/០៥០៩/០០៥ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋឆែក ស្តីពីការជំរុញ និងការការពារទៅវិញទៅមក នូវការវិនិយោគ ៣៤៥១

២~ព្រះរាជក្រឹត្យ

១២-៥-២០០៩ -ព្រះរាជក្រឹត្យនស/រកត/០៥០៩/៥០២ ស្តីពីការប្រោសព្រះរាជទាននូវគ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជាតាមលំដាប់ថ្នាក់ជូនអស់លោកចំនួន ១៣ រូប ៣៤៧៣

១២-៥-២០០៩ -ព្រះរាជក្រឹត្យនស/រកត/០៥០៩/៥០៣ ស្តីពីការប្រោសព្រះរាជទានចំពោះសពលោក **សរ ឌិន** នូវគ្រឿងឥស្សរិយយស ព្រះរាជាណា ចក្រកម្ពុជាថ្នាក់ **អស្សឫទ្ធិ** ជាកិច្ចបច្ឆាមរណៈ ៣៤៧៤

១២-៥-២០០៩ -ព្រះរាជក្រឹត្យនស/រកត/០៥០៩/៥០៤ ស្តីពីការប្រោសព្រះរាជទាននូវគ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជាតាមលំដាប់ថ្នាក់ជូនអស់លោកចំនួន ១១ រូប ៣៤៧៥

១២-៥-២០០៩ -ព្រះរាជក្រឹត្យនស/រកត/០៥០៩/៥០៥ ស្តីពីការកំណត់សមាសភាពក្រុមប្រឹក្សាគណៈវិស្វករកម្ពុជា ៣៤៧៦

១២-៥-២០០៩ -ព្រះរាជក្រឹត្យនស/រកត/០៥០៩/៥០៦ ស្តីពីការប្រោសព្រះរាជទានចំពោះឯកឧត្តម **ស៊ិន ឧុឌ្ឍី** នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជាថ្នាក់ សេនា ៣៤៧៨

១២-៥-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៥០៩/៥០៧ ស្តីពីការប្រោសព្រះរាជទានចំពោះលោកវេជ្ជបណ្ឌិត **តែម ស៊ីណយាន** នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ៣៤៧៩

១២-៥-២០០៩ -ព្រះរាជក្រឹត្យនស/រកត/០៥០៩/៥០៨ ស្តីពីការប្រោសព្រះរាជទានចំពោះឯកឧត្តម **គោស៊ី សារឿត** និងលោកជំទាវ **ខាំ ផល្លី** នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ៣៤៨០

១២-៥-២០០៩ -ព្រះរាជក្រឹត្យនស/រកត/០៥០៩/៥០៩ ស្តីពីការប្រោសព្រះរាជទានចំពោះឧត្តមសេនីយ៍ទោ **ហេង ឧុឌ្ឍី** នូវគ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា ៣៤៨១

១២-៥-២០០៩ -ព្រះរាជក្រឹត្យនស/រកត/០៥០៩/៥១០ ស្តីពីការប្រោសព្រះរាជទានចំពោះវរសេនីយឯក **ហេង ម៉ិន** និងលោក **ខាត់ សុខន** នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ៣៤៨២

១២-៥-២០០៩ -ព្រះរាជក្រឹត្យនស/រកត/០៥០៩/៥១១ ស្តីពីការប្តូរក្របខ័ណ្ឌលោក **ទ្រាំ ពិសុទ្ធ** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ថ្នាក់លេខ ១៣ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ទៅជាអនុមន្ត្រីថ្នាក់លេខ ១៣ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលក្រសួងព្រះបរមរាជវាំង ៣៤៨៣

១៩-៥-២០០៩ -ព្រះរាជក្រឹត្យនស/រកត/០៥០៩/៥១៣ ស្តីពីការប្រោសព្រះរាជទាននូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ជូននាយទាហានចំនួន ២១ រូប ៣៤៨៤

១៩-៥-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៥០៩/៥១៤ ស្តីពីការតែងតាំងឯកឧត្តម **សួន សាលីន**(SUON SALINE) ជាទីប្រឹក្សាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាមានឋានៈស្មើរដ្ឋមន្ត្រី ទទួលបន្ទុកទំនាក់ទំនងកិច្ចការ ជាមួយក្រសួងព្រះបរមរាជវាំង បន្ថែមលើមុខងារបច្ចុប្បន្ន ៣៤៨៥

១៩-៥-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៥០៩/៥១៥ ស្តីពីការប្រោសព្រះរាជទាននូវគ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជាតាមលំដាប់ថ្នាក់ជូនឯកឧត្តម លោកជំទាវ អស់លោកចំនួន ៤៥ រូប ៣៤៨៦

១៩-៥-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៥០៩/៥១៦ ស្តីពីការប្រោសព្រះរាជទាននូវគ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជាតាមលំដាប់ថ្នាក់ជូនឯកឧត្តម លោកជំទាវ អស់លោកចំនួន ៤២ រូប ៣៤៨៨

១៩-៥-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៥០៩/៥១៧ ស្តីពីការប្រោសព្រះរាជទាននូវគ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជាតាមលំដាប់ថ្នាក់ជូនឯកឧត្តម លោកជំទាវ ឧកញ៉ា អស់លោកចំនួន ៤៤ រូប ៣៤៩០

២០-៥-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៥០៩/៥២០ ស្តីពីការតែងតាំងឯកឧត្តម **ថាច់ គឹមហោ** ជាអនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ៣៤៩២

២០-៥-២០០៩ -ព្រះរាជក្រឹត្យនស/រកត/០៥០៩/៥២១ ស្តីពីការតែងតាំងជាប្រធាន អនុប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសំរាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដែលមានសមាសភាពដូចខាងក្រោម: ៣៤៩៣

II. រាជរដ្ឋាភិបាល

១. អនុក្រឹត្យ

២៥-៥-២០០៩ -អនុក្រឹត្យលេខ ៧៦ អនក្រ.បក ស្តីពីការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ៣៤៩៥

២៦-៥-២០០៩ -អនុក្រឹត្យលេខ ៧៧ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៣៤៩៧

២៧-៥-២០០៩ -អនុក្រឹត្យលេខ ៧៨ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៣៤៩៩

២៧-៥-២០០៩ -អនុក្រឹត្យលេខ ៧៩ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មការជាតិរៀបចំគោលការណ៍ណែនាំ និងនីតិវិធីក្នុងការដឹកនាំ ការការពារសារណា និងនិក្ខេបបទ ៣៥០១

គ

១៨-៥-២០០៩	-អនុក្រឹត្យលេខ ៦៦៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៣៥០៤
១៨-៥-២០០៩	-អនុក្រឹត្យលេខ ៦៦៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៣៥០៥
១៨-៥-២០០៩	-អនុក្រឹត្យលេខ ៦៦៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	៣៥០៦
១៨-៥-២០០៩	-អនុក្រឹត្យលេខ ៦៧០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៣៥០៨
១៨-៥-២០០៩	-អនុក្រឹត្យលេខ ៦៧១ អនក្រ.តត ស្តីពីការជូនមេដាយការងារ	៣៥០៩
១៩-៥-២០០៩	-អនុក្រឹត្យលេខ ៦៧២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៣៥១៤
១៩-៥-២០០៩	-អនុក្រឹត្យលេខ ៦៧៣ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា	៣៥១៧
១៩-៥-២០០៩	-អនុក្រឹត្យលេខ ៦៧៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៣៥១៨
២០-៥-២០០៩	-អនុក្រឹត្យលេខ ៦៧៥ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិជាកិច្ចបច្ចាមរណៈ	៣៥១៩
២០-៥-២០០៩	-អនុក្រឹត្យលេខ ៦៧៦ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ	៣៥២១
២០-៥-២០០៩	-អនុក្រឹត្យលេខ ៦៧៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៣៥២២
២០-៥-២០០៩	-អនុក្រឹត្យលេខ ៦៧៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៣៥២៤
២០-៥-២០០៩	-អនុក្រឹត្យលេខ ៦៧៩ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ	៣៥២៦
២០-៥-២០០៩	-អនុក្រឹត្យលេខ ៦៨០ អនក្រ.តត ស្តីពីការជូនមេដាយការងារ	៣៥២៧

២. សេចក្តីសម្រេច

២០-៥-២០០៩	- សេចក្តីសម្រេចលេខ ៣២ សសរ ស្តីពីការជ្រើសរើសពលទាហាន	៣៥២៨
២១-៥-០៩	- សេចក្តីសម្រេចលេខ ៣៣ សសរ ស្តីពី ការបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីសម្របសម្រួលរៀបចំខ្លឹមសារសម្រាប់កិច្ចប្រជុំលើកទី ៥ ស្តីពីកិច្ចសហប្រតិបត្តិការនិងការអភិវឌ្ឍរវាងបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម	៣៥២៩
២៥-៥-០៩	- សេចក្តីសម្រេចលេខ ៣៤ សសរ ស្តីពីការចាត់តាំងសមាជិករាជរដ្ឋាភិបាល ដើម្បីចូលរួមជាអធិបតីក្នុងពិធីប្រកាសចូលកាន់តំណែងរបស់ក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ខេត្ត	៣៥៣២

៣. សារាចរ

២៧-៥-០៩	- សារាចរលេខ ០២ សរ ស្តីពីយន្តការត្រួតពិនិត្យ តាមដាន ថ្លៃសម្ភារៈកសិកម្ម	៣៥២២

III. ការងារបណ្តាក្រសួង

១. ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ

១៨-៥-០៩	- ប្រកាសលេខ ១៧៦ ប្រក.កសក.ប ស្តីពីការបង្កើតការិយាល័យកសិកម្មស្រុករុក្ខគីរីចំណុះមន្ទីរកសិកម្មខេត្តបាត់ដំបង	៣៥៣៥

២_ទីស្តីការរដ្ឋមន្ត្រីក្រសួងការពារជាតិ

២២-៥-០៩ - - ប្រកាសលេខ ០៦៤/២០០៩-ប្រក. ស្តីពីការចេញប័ណ្ណ ផ្លាកលេខចរាចរ និងសញ្ញាសំគាល់ស្ថាប័ន កងឯកភាព ក្នុងកងយោធពលខេមរភូមិន្ទ ៣៥៣៩

៣_ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២៥-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥២៧៤ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស្មាត បរ ផាយល៍ អេនជីនារីង** ៣៥៤៤

២៥-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥២៧៥ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សូដា អ៊ីនវេសមេន** ៣៥៤៦

២៥-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥២៧៦ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សូយ៉ា អ៊ីនវេសមេន** ៣៥៤៨

២៥-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥២៧៨ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ារី អ៊ីនវេសមេន** ៣៥៥០

២៥-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥២៧៩ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វី_លីង អ៊ីនធើណេសិនណល** ៣៥៥២

២៥-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥២៨០ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ី.អេស.អ. ខនស្ត្រាក់សិន ខូ អិលធីឌី** ៣៥៥៤

២៦-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥៣០៣ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស្ពារ ឌីវេឡុបមេន ខមភេនី អិលធីឌី** ៣៥៥៦

២៦-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥៣០៤ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គល ពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សេលឡាញ ចាយធេននៀម អិចផ្លរេសិន ខូអិលធីឌី** ៣៥៥៨

២៦-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥៣០៥ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហាន់អ៊ីល ខនសាល់ធីង** ៣៥៦០

ព្រះរាជក្រម

នស/រកម/០៥០៩/០០៤

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃរដ្ឋគុយ៉ែត ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី ២ នីតិកាលទី ៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៥ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ច្បាប់

ស្តីពី

ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង
ស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេសរវាង
រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃរដ្ឋគុវ៉ែត

មាត្រា ១.-

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃរដ្ឋគុវ៉ែត ដែលធ្វើនៅ រាជធានីភ្នំពេញ នាថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៨ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់ មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវមន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៩ ខែឧសភាឆ្នាំ ២០០៩

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣/រម.០៥០៩.៥១៦

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខា

គាត ឈន់

លេខ : ៤៧៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

[illegible] ជិនកេន

3/3

កិច្ចព្រមព្រៀងស្តីពី
សហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស
រវាងរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលនៃរដ្ឋគូវ៉ែត

រាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលនៃរដ្ឋគូវ៉ែត (ដែលចាប់ពីពេលនេះហៅថា ភាគីហត្ថលេខី)

ដោយពិចារណាលើទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តការរវាងប្រទេសទាំងពីរ

មានបំណងដើម្បីពង្រឹង និងអភិវឌ្ឍន៍កិច្ចសហប្រតិបត្តការសេដ្ឋកិច្ច និងបច្ចេកទេសរវាងប្រទេសទាំងពីរ ដោយឈរលើផលប្រយោជន៍រួម និងអត្ថប្រយោជន៍ទៅវិញទៅមក ដើម្បីធានាដល់កាលៈទេសៈសមស្រប ដើម្បីលើកទឹកចិត្តដល់ការវិនិយោគរវាងប្រទេសទាំងពីរ បានព្រមព្រៀងគ្នាដូចខាងក្រោម :

មាត្រា ១

ភាគីហត្ថលេខី ត្រូវបង្កើនកិច្ចសហប្រតិបត្តការសេដ្ឋកិច្ច និងបច្ចេកទេស រវាងប្រទេសទាំងពីរ នៅក្នុងផលប្រយោជន៍រួម ។

មាត្រា ២

វិស័យនៃកិច្ចសហប្រតិបត្តិការ ដែលបានចែងក្នុងកិច្ចព្រមព្រៀងនេះ ជាទូទៅមាន វិស័យសេដ្ឋកិច្ច ហិរញ្ញវត្ថុ ពាណិជ្ជកម្ម ធនាគារ ឧស្សាហកម្ម ថាមពល ទេសចរណ៍ និងការអភិវឌ្ឍន៍បច្ចេកទេស ហើយនឹងវិស័យផ្សេងៗទៀត ដែលភាគីហត្ថលេខីទាំងពីរបានព្រមព្រៀង ។

មាត្រា ៣

ភាគីហត្ថលេខី ត្រូវជំរុញកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស រវាងស្ថាប័ននីមួយៗរបស់ពួកគេ នៅក្នុងប្រទេសទាំងពីរ រួមទាំងការលើកទឹកចិត្តដល់ផ្នែកឯកជន ដើម្បីបង្កើតការបណ្តាក់ទុនរួម និងបង្កើតក្រុមហ៊ុននៅក្នុងវិស័យផ្សេងៗនៃកិច្ចសហប្រតិបត្តិការ ការផ្លាស់ប្តូរទស្សនៈកិច្ចអ្នកតំណាង និងគណៈប្រតិភូសេដ្ឋកិច្ច និងបច្ចេកទេស

រវាងប្រទេសទាំងពីរ និងរៀបចំការតាំងពិពណ៌សំរាប់ពង្រីងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និង បច្ចេកទេសទ្វេភាគី ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានដែលកំពុងអនុវត្តក្នុងប្រទេសទាំងពីរ ។

មាត្រា ៤

ភាគីហត្ថលេខី ត្រូវអង្កេតមើល ខ ចែងនៃអង្គការពាណិជ្ជកម្មពិភពលោក ហើយកិច្ចព្រមព្រៀងនានា ត្រូវផ្អែកតាមកាតព្វកិច្ចនៃអង្គការនេះ ។

មាត្រា ៥

ភាគីហត្ថលេខី ត្រូវលើកទឹកចិត្តដល់ការវិនិយោគ និងលំហូរនៃមូលធន ទំនិញ និងសេវាកម្ម រវាងប្រទេសទាំងពីរ ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានដែលកំពុងអនុវត្តក្នុងប្រទេសទាំងពីរ ។

មាត្រា ៦

១. ដើម្បីធានាដល់ការអនុវត្តន៍កិច្ចព្រមព្រៀងនេះ គណៈកម្មាធិការចម្រុះមួយ នឹងត្រូវបានបង្កើតឡើង ដោយមានតំណាងមកពីភាគីនៃភាគីហត្ថលេខីទាំងសងខាង ។

២. គណៈកម្មាធិការចម្រុះនេះ ត្រូវជួបប្រជុំគ្នាជារៀងរាល់ឆ្នាំ តាមសំណើរបស់ភាគីហត្ថលេខីណាមួយ តាមរបៀបប្តូរវេន នៅក្នុងរដ្ឋធានីរបស់ភាគីហត្ថលេខីទាំងពីរ ។

៣. តំណាងម្នាក់ពីក្រសួងហិរញ្ញវត្ថុនៃប្រទេសគូវ៉ែត និងតំណាងម្នាក់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើជាសហប្រធាននៃគណៈកម្មាធិការនេះ ។

៤. គណៈកម្មាធិការចម្រុះនេះ ត្រូវពិចារណាលើបញ្ហាដូចខាងក្រោម :

ក. រកមធ្យោបាយដោះស្រាយការអនុវត្តន៍មាត្រានានា នៅក្នុងកិច្ចព្រមព្រៀងនេះ

ខ. ធ្វើការជម្រុញ និងសម្របសម្រួលកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេសរវាងភាគីហត្ថលេខី

គ. លើកសំណើនូវវិស័យថ្មីបន្ថែមទៀតនៃកិច្ចសហប្រតិបត្តិការនៅក្នុងវិស័យសេដ្ឋកិច្ច និងបច្ចេកទេស ។

មាត្រា ៧

ប្រសិនបើគិតថាចាំបាច់ ភាគីហត្ថលេខី ត្រូវធ្វើបញ្ចប់កិច្ចព្រមព្រៀងដោយឡែកៗ ដោយផ្អែកលើមូលដ្ឋាន នៃកិច្ចព្រមព្រៀងនេះ ទាក់ទងនឹងវិស័យនានានៃកិច្ចសហប្រតិបត្តិការ ដូចមានយោងតាមមាត្រា ២ ខាងលើ និងគម្រោងពិសេសនានា ដែលអាចត្រូវបានព្រមព្រៀងគ្នារវាងប្រទេសទាំងពីរ ។

មាត្រា ៨

១. កិច្ចព្រមព្រៀងនេះ ត្រូវចូលជាធរមានចាប់ពីកាលបរិច្ឆេទ នៃការជូនដំណឹងជាលាយលក្ខណ៍អក្សរចុង ក្រោយ ដែលធ្វើដោយភាគីហត្ថលេខីមួយ ជូនទៅភាគីម្ខាងទៀត តាមរយៈការទូតថា ខ្លួនបានបំពេញ នីតិវិធីច្បាប់ ដែលតម្រូវសម្រាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងរួចហើយ ។

២. កិច្ចព្រមព្រៀងនេះ អាចធ្វើវិសោធនកម្មប្រសិនជាមានការយល់ព្រមដោយភាគីហត្ថលេខីទាំងពីរ ។ ការធ្វើ វិសោធនកម្មចាប់ផ្តើមមានប្រសិទ្ធិភាពអនុវត្តដោយអនុលោមតាមនីតិវិធី ដែលលើកឡើងនៅក្នុងកថាខ័ណ្ឌ ខាងដើម ។

៣. កិច្ចព្រមព្រៀងនេះ ត្រូវនៅជាធរមានសម្រាប់រយៈពេលប្រាំឆ្នាំ ហើយមានសុពលភាពសម្រាប់រយៈពេល ប្រាំ ឆ្នាំបន្ថែមជាស្វ័យប្រវត្តិ ប្រសិនគ្មានភាគីណាមួយធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ ពីចេតនាបញ្ចប់ កិច្ចព្រមព្រៀង ក្នុងរយៈពេលប្រាំមួយខែ មុនកាលបរិច្ឆេទផុតសុពលភាពនៃកិច្ចព្រមព្រៀងនេះ ។

មាត្រា ៩

ការបញ្ចប់កិច្ចព្រមព្រៀងនេះ នឹងមិនប៉ះពាល់ដល់សុពលភាព ឬរយៈពេលជាក់លាក់នៃកិច្ចព្រមព្រៀង គម្រោងនានា និងសកម្មភាពដែលមានចែងនៅក្នុងមាត្រា ៧ ឡើយ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៨ ជាពីរច្បាប់ដើម ជាភាសាខ្មែរ ភាសាអារ៉ាប់ និងភាសា អង់គ្លេស ដែលអត្ថបទទាំងអស់មានយថាភូតដូចគ្នា ។ ក្នុងករណីមានការបកស្រាយខុសគ្នា អត្ថបទជាភាសាអង់គ្លេស នឹងត្រូវប្រើប្រាស់ជាគោល ។

ជ. រាជរដ្ឋាភិបាលកម្ពុជា	ជ. រដ្ឋាភិបាលនៃរដ្ឋគុវ៉ែត
ហោ ណាំហុង	មូស្តាហ្វា ហ្សាស៊ីម អាល់សាម៉ាលី
ឧបនាយករដ្ឋមន្ត្រី	រដ្ឋមន្ត្រីហិរញ្ញវត្ថុ
រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	

AGREEMENT
BETWEEN THE ROYAL GOVERNMENT OF CAMBODIA
AND
THE GOVERNMENT OF THE STATE OF KUWAIT
FOR ECONOMIC AND TECHNICAL CO-OPERATION

The Royal Government of Cambodia and the Government of the State of Kuwait (hereinafter referred to as the "Contracting Parties");

Considering relations of friendship and cooperation between the two countries;

Desires to consolidate and develop the economic and technical co-operation between the two countries on the basis of common benefits and mutual interest to ensure the suitable circumstances to encourage the investments between their countries;

Have agreed as follows:

Article 1

The Contracting Parties shall promote the economic and technical co-operation between the two countries in the fields of common interests.

Article 2

The co-operation mentioned in this Agreement are included, but not limit to the fields of general the economic, finance, commerce, banking, industry, energy, tourism, and technical development and any other fields, in which both Contracting Parties to be agreed upon.

Article 3

The Contracting Parties shall promote economic and technical co-operation between their respective institutions in the two countries, including the encouragement of the private sector for the establishment of joint ventures and companies in the different spheres of co-operation, the exchange of visits by economic and technical representatives and delegations between them and the setting up of exhibitions for the consolidation of the bilateral economic and technical co-operation, in accordance with their applicable laws and regulations in the two countries.

Article 4

The contracting Parties shall observe the provisions of the World Trade Organization (WTO) and the agreements stemming there from by virtue of their obligations to the Organization.

Article 5

The Contracting Parties shall encourage investment and the flow of capital, goods and services between their respective countries, in accordance with their applicable laws and regulations in the two countries.

Article 6

1. With a view to ensuring the implementation of this Agreement, a Joint Committee shall be established and composed of representative from both Contracting Parties.
2. The Committee shall meet annually at the request of either Contracting Party alternately in the capitals of the Contracting Parties.
3. A representative from the Ministry of Economy and Finance of the Kingdom of Cambodia and the Ministry of Finance of the State of Kuwait shall co-chair the Joint Committee.
4. The Joint Committee shall consider the following:
   a. working out implementation of articles in this Agreement.
   b. promoting and coordinating the economic and technical co-operation between the Contracting Parties.
   c. proposing other new means sectors of cooperation in the economic and technical fields.

Article 7

If deemed necessary, the Contracting Parties shall conclude specific agreements to be based on this Agreement concerning the fields of co-operation referred to above in article (2) and special projects that may be agreed upon between the two countries.

Article 8

1. This Agreement shall enter into force from the date of the last notification whereby one of the Contracting Parties informs the other in writing through diplomatic channels that it has satisfied the constitutional procedures required for its entry into force.

2. This Agreement can be amended with the consent of both Contracting Parties. Amendment will be effective according to the procedures mentioned in the previous paragraph.

3. This Agreement shall remain in force for a period of five years and automatically renewed for the same periods, unless either Contracting Parties inform the other in writing about his intention to terminate this Agreement within six months before the termination of this agreement.

Article 9

The termination of this Agreement shall not affect the validity or the duration of any specific agreements, projects and activities made under Article 7.

Done in Phnom Penh on 4th August 2008 in two original copies, in Khmer, the Arabic and English languages, all texts being equally authentic. In case of any divergence of interpretation the English text shall prevail.

FOR THE ROYAL GOVERNMENT OF CAMBODIA	FOR THE GOVERNMENT OF THE STATE OF KUWAIT
HOR Namhong **Deputy Prime Minister** **Minister of Foreign Affairs and International Cooperation**	**Mustafa Jassim Al-Shamali** **Minister of Finance**

ព្រះរាជក្រម

នស/រកម/០៥០៩/០០៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋឆែក ស្តីពីការជំរុញ និងការការពារទៅវិញទៅមកនូវការវិនិយោគ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី ២ នីតិកាលទី ៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៥ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

៚

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋស្លូវ៉ាគី ស្តីពីការជំរុញនិងការការពារទៅវិញទៅមកនូវការវិនិយោគ

មាត្រា ១.–

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋស្លូវ៉ាគីស្តីពីការជំរុញនិងការការពារទៅវិញទៅមកនូវការវិនិយោគ ដែលធ្វើនៅរាជធានីភ្នំពេញ នាថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៨ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.–

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៩ ខែឧសភាឆ្នាំ ២០០៩

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកម.០៥០៥.៥១៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខា

គាត ឈន់

លេខ : ៤៧៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ជំអាន

កិច្ចព្រមព្រៀង
រវាង
រដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
និង
រដ្ឋាភិបាល នៃ សាធារណរដ្ឋ ឆែក
ស្តីពី
ការជំរុញ និង ការការពារទៅវិញទៅមកនូវការវិនិយោគ

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋ ឆែក (ចាប់ពីពេលនេះតទៅហៅថា "ភាគីជាប់កិច្ចសន្យា")

ដោយមានគោលបំណង អភិវឌ្ឍន៍នូវកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ដើម្បីផលប្រយោជន៍ទៅវិញទៅមករវាងរដ្ឋទាំងពីរ

ដោយមានចេតនាបង្កើត និងរក្សាបាននូវលក្ខខណ្ឌអំណោយផលសំរាប់ការវិនិយោគនៃអ្នកវិនិយោគរបស់រដ្ឋមួយនៅលើទឹកដី នៃរដ្ឋមួយទៀត និង

ដោយទទួលស្គាល់ថា ការជំរុញ និងការការពារទៅវិញទៅមកនូវការវិនិយោគតាមរយៈកិច្ចព្រមព្រៀងនេះ លើកទឹកចិត្តឱ្យមានការផ្តួចផ្តើមធុរកិច្ចនានា ក្នុងវិស័យនេះ

បានព្រមព្រៀងគ្នាដូចតទៅ :

មាត្រាទី ១
និយមន័យ

ចំពោះគោលបំណងនៃកិច្ចព្រមព្រៀងនេះ :

១- ពាក្យ " **វិនិយោគទុន** "មានរួមបញ្ចូលនូវរាល់ទ្រព្យសម្បត្តិដែលបានវិនិយោគភ្ជាប់ទៅនឹងសកម្មភាពសេដ្ឋកិច្ចទាំងឡាយ ធ្វើឡើងដោយអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាង នៅលើទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ដោយអនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិរបស់ភាគីម្ចាស់ផ្ទះ និងរួមមានជាអាទិ៍ តែពុំកំណត់តែត្រឹមអ្វីដូចមានរៀបរាប់ខាងក្រោមនេះឡើយ:

/ក/ ចលនទ្រព្យ និង អចលនទ្រព្យ រួមទាំងកម្មសិទ្ធិដទៃទៀត ដូចជា ការបញ្ចាំ សិទ្ធិនៃការដេកហ៊ុត ឬការសន្យា

/ខ/ ភាគហ៊ុន ហ៊ុន ប័ណ្ណបំណុល របស់ក្រុមហ៊ុន និងទ្រង់ទ្រាយផ្សេងៗទៀតនៃការរួមចំណែក ទៅក្នុងសហគ្រាស

/គ/ ការទាមទារប្រាក់ ឬការទាមទារនូវការអនុវត្តកិច្ចសន្យាដែលមានតំលៃហិរញ្ញវត្ថុទាក់ទងទៅនឹងការវិនិយោគ

/ឃ/ សិទ្ធិកម្មសិទ្ធិបញ្ញា ដែលមានន័យថាជា ពាណិជ្ជសញ្ញា ម៉ាកយី តំរោងប្លង់ឧស្សាហកម្ម ក្បួនខ្នាតបច្ចេកវិជ្ជា ស្នាដៃយល់ដឹង ការសម្ងាត់ធុរកិច្ច ពាណិជ្ជនាម និងកិត្តិនាមពាណិជ្ជកម្មដែលទាក់ទងដល់ការវិនិយោគ

/ង/ សិទ្ធិដែលបានទទួលដោយច្បាប់ ឬតាមរយៈកិច្ចសន្យា និងអាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតដែលយោងដោយច្បាប់ រាប់បញ្ចូលទាំងសម្បទានក្នុងការស្វែងរក ការទាញយកផល ការដាំដុះ ឬការធ្វើអាជីវកម្មធនធានធម្មជាតិ

ការប្រែប្រួលទ្រង់ទ្រាយនៃទ្រព្យសម្បត្តិណាមួយ ដែលត្រូវបានវិនិយោគ មិនមានផលប៉ះពាល់ដល់លក្ខណៈសម្បត្តិនៃការវិនិយោគឡើយ ។

២- ពាក្យ " **អ្នកវិនិយោគ** " មានន័យថា រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលបានវិនិយោគនៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត :

/ក/ ពាក្យថា "រូបវន្តបុគ្គល" មានន័យថា រូបវន្តបុគ្គលណាមួយដែលមានសញ្ជាតិនៃភាគីជាប់កិច្ចសន្យាណាមួយ ដោយអនុលោមទៅតាមច្បាប់របស់ភាគីជាប់កិច្ចសន្យានោះ ។

/ខ/ ពាក្យថា " នីតិបុគ្គល " មានន័យថា ចំពោះភាគីនីមួយៗ គឺអង្គភាពដែលស្ថិតនៅក្រោម ឬបង្កើតឡើង ដោយអនុលោម និងទទួលស្គាល់ជានីតិបុគ្គល ស្របតាមច្បាប់ និងបទប្បញ្ញត្តិនៃភាគីជាប់កិច្ចសន្យា ដែលមានទីស្នាក់ការ នៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យានោះ ។

៣- ពាក្យ " **និព្វផល** " មានន័យថា :ចំណូលបានមកពីការវិនិយោគ និងមានជាអាទិ៍ដែលមិនកំណត់ត្រឹមនេះឡើយ នូវប្រាក់ចំណេញការប្រាក់ទាក់ទងទៅនឹងប្រាក់កម្ចី ផលកំរៃ ភាគហ៊ុន ភាគលាភ កំរៃឈ្នួល ឬកំរៃ ។

៤- ពាក្យ " **ទឹកដី** " មានន័យថា :

/ក/ ចំពោះព្រះរាជាណាចក្រកម្ពុជា គឺ ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលរួមមានតំបន់សមុទ្ររាប់បញ្ចូលទាំងបាតសមុទ្រ និងស្រទាប់ដីក្រោមបាតសមុទ្រ ដែលជាប់នឹងព្រំដែនខាងក្រៅនៃបាតសមុទ្រ ហើយដែលព្រះរាជាណាចក្រកម្ពុជាមានសិទ្ធិគ្រប់គ្រងអធិបតេយ្យភាព ឬ

កាតព្វកិច្ចគ្រប់គ្រងតាមផ្លូវច្បាប់ ដោយអនុលោមទៅតាមច្បាប់ជាតិ ដែលត្រូវស្របទៅនឹងច្បាប់អន្តរជាតិ ។

/ខ/ ចំពោះសាធារណរដ្ឋឆែក គឺទឹកដីនៃសាធារណរដ្ឋឆែក ទីដែលសាធារណរដ្ឋឆែកអនុវត្តអធិបតេយ្យភាព សិទ្ធិត្រួតត្រា និងកាតព្វកិច្ចគ្រប់គ្រង ស្របទៅនឹងច្បាប់អន្តរជាតិ ។

មាត្រា ២
ការជំរុញ និង ការការពារការវិនិយោគ

១- ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវលើកទឹកចិត្ត និងបង្កើតភាពអនុគ្រោះដល់អ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ក្នុងការធ្វើវិនិយោគលើទឹកដីរបស់ខ្លួន ហើយទទួលស្គាល់ការវិនិយោគនោះ ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួន ។

២- ការវិនិយោគ របស់អ្នកវិនិយោគ នៃភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវទទួលបានការយល់ព្រមគ្រប់ពេលវេលា នូវប្រព្រឹត្តិកម្មដោយត្រឹមត្រូវ និងស្មើភាព និងត្រូវបានទទួលនូវកិច្ចការពារ និងមានសុវត្ថិភាពពេញលេញ នៅលើទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ។

មាត្រា ៣
ប្រព្រឹត្តិកម្មជាតិ និងប្រព្រឹត្តិកម្មនៃប្រជាជាតិដែលទទួលនូវការអនុគ្រោះបំផុត

១- ភាគីជាប់កិច្ចសន្យានីមួយ ៗ ត្រូវផ្តល់នូវការយល់ព្រមក្នុងទឹកដីរបស់ខ្លួន លើការធ្វើវិនិយោគ និងទិន្នផលរបស់អ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតនូវប្រព្រឹត្តិកិច្ចដោយត្រឹមត្រូវ និងយុត្តិធម៌ និងមិនតិចជាងអ្វីដែល ខ្លួនបានផ្តល់អោយការវិនិយោគ និងទិន្នផលរបស់អ្នកវិនិយោគជាជនជាតិខ្លួន ឬការវិនិយោគ និង ទិន្នផលរបស់អ្នកវិនិយោគនៃតតិយរដ្ឋណាមួយនោះឡើយ ឱ្យតែប្រព្រឹត្តិកម្មនោះមានលក្ខណៈអនុគ្រោះច្រើន ចំពោះអ្នកវិនិយោគដែលពាក់ព័ន្ធ ។

២- ភាគីជាប់កិច្ចសន្យា ត្រូវផ្តល់ការយល់ព្រមក្នុងទឹកដីរបស់ខ្លួនទៅឱ្យអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតទាក់ទងនឹងការគ្រប់គ្រង ការថែរក្សា ការប្រើប្រាស់ ការទទួលបាន ឬការចាត់ចែងនៃការវិនិយោគនូវប្រព្រឹត្តិកម្ម ដែលត្រឹមត្រូវ និងយុត្តិធម៌ មិនតិចជាងអ្វីដែលខ្លួនបានផ្តល់ឱ្យទៅឱ្យអ្នកវិនិយោគរបស់ខ្លួន ឬអ្នកវិនិយោគនៃតតិយរដ្ឋណាមួយនោះឡើយ ឱ្យតែប្រព្រឹត្តកម្មនោះ មានលក្ខណៈអនុគ្រោះច្រើន ចំពោះអ្នកវិនិយោគដែលពាក់ព័ន្ធ ។

៣- បញ្ញត្តិនៃប្រព្រឹត្តិកម្មជាតិ និងប្រព្រឹត្តិកម្មនៃប្រជាជាតិដែលទទួលនូវការអនុគ្រោះបំផុតនៃមាត្រានេះ មិនត្រូវបានយកទៅអនុវត្ត ចំពោះផលប្រយោជន៍ ដែលភាគីជាប់កិច្ចសន្យាម្ខាងត្រូវទទួលបាន ដោយអនុលោមទៅតាមកាតព្វកិច្ចរបស់ខ្លួន ក្នុងនាមជាសមាជិកនៃសហព័ន្ធគយ សហព័ន្ធសេដ្ឋកិច្ច ឬសហព័ន្ធរូបិយវត្ថុ តំបន់ទីផ្សាររួម ឬតំបន់ពាណិជ្ជកម្មសេរីនោះឡើយ ។

៤- ភាគីជាប់កិច្ចសន្យាយល់ច្បាស់ពីកាតព្វកិច្ចនៃភាគីជាប់កិច្ចសន្យា ដែលជាសមាជិកនៃ សហព័ន្ធគយ សហព័ន្ធសេដ្ឋកិច្ច ឬសហព័ន្ធរូបិយវត្ថុ តំបន់ទីផ្សាររួម ឬតំបន់ពាណិជ្ជកម្មសេរីនេះ មានរួមបញ្ចូលផងដែរ អំពីកាតព្វកិច្ចដែលកំណត់ឡើងដោយកិច្ចព្រមព្រៀងអន្តរជាតិ ឬ កិច្ចព្រមព្រៀងបត្យាប័ននៃសហព័ន្ធគយ សហព័ន្ធសេដ្ឋកិច្ច ឬសហព័ន្ធរូបិយវត្ថុ តំបន់ទីផ្សាររួម ឬតំបន់ពាណិជ្ជកម្មសេរីនោះ ។

៥- បញ្ញត្តិនៃមាត្រានេះ មិនត្រូវបានបកស្រាយថា ជាការចាប់បង្ខំភាគីជាប់កិច្ចសន្យាម្ខាង ឱ្យបើកទូលាយដល់អ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ឬ ដល់ការវិនិយោគ ឬទិន្នផលនៃអ្នកវិនិយោគនោះ នូវផលប្រយោជន៍នៃប្រព្រឹត្តិកម្មណាមួយ ភាពអនុគ្រោះ ឬបុព្វសិទ្ធិ ដែលបានបើកទូលាយដោយភាគីជាប់កិច្ចសន្យាមុននោះ ដោយផ្អែកទៅនឹងកិច្ចព្រមព្រៀងអន្តរជាតិ ឬការសម្របសម្រួលណាមួយ ដែលទាក់ទងទាំងស្រុង ឬជាសំខាន់ទៅនឹងកិច្ចការពន្ធដារនោះឡើយ ។

មាត្រាទី ៤
សំណងសំរាប់ការខាតបង់

១- នៅពេលដែលការវិនិយោគធ្វើឡើងដោយអ្នកវិនិយោគ នៃភាគីជាប់កិច្ចសន្យាណាមួយទទួលរងនូវការខាតបង់ ដែលបណ្តាលមកពីសង្គ្រាម ឬជំលោះអាវុធ ការប្រកាសប្រទេសជាតិស្ថិតក្នុងភាពអាសន្ន បដិវត្ត កុប្បកម្ម ភាពចលាចលស៊ីវិល ឬហេតុការណ៍ប្រហាក់ប្រហែល នៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត អ្នកវិនិយោគនោះត្រូវតែបានទទួលការយល់ព្រមពីភាគីជាប់កិច្ចសន្យា ដែលជាម្ចាស់ទឹកដីនោះនូវប្រព្រឹត្តិកម្ម ដូចជាការធ្វើឱ្យដូចដើមវិញ ការប៉ះប៉ូវសំណង ឬ ដំណោះស្រាយណាមួយផ្សេងទៀត មិនតិចជាងភាពអនុគ្រោះ ដែលភាគីជាប់កិច្ចសន្យាជាម្ចាស់ផ្ទះបានផ្តល់ឱ្យអ្នកវិនិយោគរបស់ជនជាតិខ្លួន ឬអ្នកវិនិយោគនៃតតិយជនណាមួយនោះឡើយ ។

២- ដោយមិនឱ្យមានផលប៉ះពាល់ដល់កថាខ័ណ្ឌទី១ នៃមាត្រានេះ អ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងដែលស្ថិតនៅក្នុងហេតុការណ៍ណាមួយផ្អែកលើកថាខ័ណ្ឌនេះ បានរងនូវការខាតបង់នៅក្នុងទឹកដី

នៃភាគី ជាប់កិច្ចសន្យាម្ខាងទៀត ដែលបណ្តាលមកពី :

/ក/ ការរឹបអូសទ្រព្យសម្បត្តិ ដោយកំលាំងទ័ព ឬអាជ្ញាធរនៃភាគីម្ចាស់ផ្ទះ ឬ

/ខ/ ការបំផ្លាញទ្រព្យសម្បត្តិរបស់ខ្លួន ដោយកំលាំងទ័ព ឬដោយអាជ្ញាធរនៃភាគីម្ចាស់ផ្ទះ ដែលមិនមែនជាមូលហេតុនៃសកម្មភាពប្រយុទ្ធគ្នា ដែលមិនស្ថិតក្នុងស្ថានភាពចាំបាច់ទេនោះនឹងត្រូវទទួលបាននូវសំណងតាមស្ថានភាពដើមវិញ ឬសំណងគ្រប់ចំនួន នៃការខាតបង់ដែលបង្កឡើងនាពេលរឹបអូស ឬបច្ច័យនៃការបំផ្លាញទ្រព្យសម្បត្តិ ។ ការទូទាត់សំណង ត្រូវធ្វើដោយរូបិយបណ្ណដែលអាចផ្ទេរ និងប្តូរបានដោយសេរី និងពុំមានការពន្យារពេលឡើយ ។

មាត្រាទី ៥
ការដកហូត

១- ការវិនិយោគនៃអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាណាមួយមិនត្រូវបានធ្វើជាតូបនីយកម្ម មិនត្រូវបានដកហូត ឬប្រកាន់យកនូវវិធានការណ៍ ដែលមានឥទ្ធិពលស្មើគ្នាទៅនឹងការធ្វើជាតូបនីយកម្ម ឬការដកហូត (នៅទីនេះនិយាយសំដៅលើការដកហូត) នៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតឡើយលើកលែងតែសំរាប់គោលបំណងជាផលប្រយោជន៍សាធារណៈ ។ ការដកហូតត្រូវប្រព្រឹត្តិទៅតាមនីតិវិធីនៃច្បាប់ លើមូលដ្ឋានគ្មានការរើសអើង និង ភ្ជាប់ជាមួយនូវការទូទាត់សំណងយ៉ាងឆាប់រហ័សគ្រប់ចំនួននិងជាក់ស្តែង ។ សំណងត្រូវមានទឹកប្រាក់ស្មើនឹងតំលៃនៃការវិនិយោគ ដែលបានដកហូត នៅមុនពេលដែលការដកហូត ឬព្រឹត្តិការណ៍នៃការដកហូតបានផ្សាយចេញជាសាធារណៈ ។ សំណងត្រូវរួមបញ្ចូលផងដែរនូវការប្រាក់គិតចាប់ពីថ្ងៃដកហូត ដោយមិនមានការពន្យារពេល មានប្រសិទ្ធិភាពដំណើការ និងត្រូវធ្វើដោយរូបិយបណ្ណដែលអាចផ្ទេរ និងប្តូរបានដោយសេរី ។

២- អ្នកវិនិយោគដែលទទួលរងនូវការដកហូត មានសិទ្ធិធ្វើការពិនិត្យឡើងវិញជាប្រញាប់ តាមរយៈតុលាការ ឬអាជ្ញាធរឯករាជ្យនៃភាគីជាប់កិច្ចសន្យាដែលការវិនិយោគបានធ្វើនៅក្នុងទឹកដីនោះ ចំពោះករណីនិងការវាយតំលៃនៃការវិនិយោគរបស់ខ្លួន ស្របតាមគោលការណ៍កំណត់នៃមាត្រានេះ ។

មាត្រានី ៦
ការផ្ទេរ

១- ដោយមិនឱ្យមានផលប៉ះពាល់ដល់វិធានការដែលបានអនុម័តដោយសហគមន៍អឺរ៉ុប ភាគីជាប់កិច្ចសន្យាត្រូវធានាការទូទាត់ដែលត្រូវផ្ទេរទាក់ទងទៅនឹងការវិនិយោគ និងទិន្នផល ។ ការផ្ទេរនឹងត្រូវធ្វើឡើងដោយរូបិយប័ណ្ណដែលអាចប្តូរបានដោយសេរី ដោយគ្មានការដាក់កំហិត និងគ្មានការពន្យាពេល ។ ការផ្ទេរនេះរាប់បញ្ចូលនូវទឹកប្រាក់ជាពិសេស តែមិនកំណត់ដាច់ខាតតែត្រឹមនេះទេ :

/ក/ ដើមទុន និងទឹកប្រាក់បន្ថែម ដើម្បីទ្រទ្រង់ ឬបង្កើនវិនិយោគ

/ខ/ ប្រាក់ចំណេញ ការប្រាក់ ភាគលាភ និងចំណូលចំពោះមុខផ្សេងៗ

/គ/ មូលនិធិសំរាប់ទូទាត់ប្រាក់កម្ចី

/ឃ/ កំរៃសួយសារ ឬថ្លៃឈ្នួល

/ង/ ប្រាក់ដែលបានមកពីការលក់ ការជំរះបញ្ជីនៃការវិនិយោគ

/ច/ ចំណូលនៃបុគ្គលិក មកពីបរទេស ដែលបំរើការងារ និងអនុញ្ញាតឱ្យធ្វើការងារ ដែលភ្ជាប់ទៅនឹងការវិនិយោគ នៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ។

២- សំរាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ អត្រាប្តូរប្រាក់ គឺគិតទៅតាមអត្រាទីផ្សារនៃអាជីវកម្មចំពោះមុខនាថ្ងៃផ្ទេរ លើកលែងតែមានការព្រមព្រៀងផ្សេងទៀត ។

៣- ការផ្ទេរត្រូវបានចាត់ទុកថានឹងប្រព្រឹត្តទៅដោយ " មិនមានការពន្យាពេល " ដូចអត្ថន័យនៃកថាខ័ណ្ឌ (១) នៃមាត្រានេះ ក្នុងរយៈពេលចាំបាច់ជាធម្មតា សំរាប់ការបំពេញបែបបទផ្ទេរ ។

មាត្រា ៧
ឧបរនេសកម្ម

១- ក្នុងករណីដែលភាគីជាប់កិច្ចសន្យាមួយ ឬភ្នាក់ងារដែលបានតែងតាំងបានផ្តល់នូវការទូទាត់ទៅឱ្យអ្នកវិនិយោគរបស់ខ្លួនក្រោមកិច្ចធានារ៉ាប់រងដែលខ្លួនបានយល់ព្រមចំពោះការវិនិយោគនៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ភាគីម្ចាស់ផ្ទះត្រូវទទួលស្គាល់:

/ក/ ការផ្ទេរនូវសិទ្ធិ អំណាច ឬការទាមទាររបស់អ្នកវិនិយោគ ស្របតាមច្បាប់ ឬអនុលោមតាមការធ្វើពាណិជ្ជកម្មស្របច្បាប់នៅក្នុងប្រទេសនោះ ជូនភាគីជាប់កិច្ចសន្យា ដែលបានផ្ទេរ ឬភ្នាក់ងារដែលបាន

ទទួលការចាត់តាំងផងដែរ ។

/ខ/ ថាភាគីជាប់កិច្ចសន្យារបស់អ្នកវិនិយោគ ឬភ្នាក់ងាររបស់ភាគីនេះ មានសិទ្ធិ ដោយផ្អែកតាមការធ្វើឧបាទេសកម្ម ដើម្បីអនុវត្តនូវសិទ្ធិអំណាច និងការទាមទារនៃអ្នកវិនិយោគនោះ ហើយក៏ទទួលខុសត្រូវចំពោះកាតព្វកិច្ចដែលទាក់ទងទៅនឹងការវិនិយោគផងដែរ ។

២- ឧបាទេសកម្ម នូវសិទ្ធិអំណាច និងការទាមទារ មិនត្រូវហួសពីសិទ្ធិ និងអំណាចនៃអ្នកវិនិយោគដែលបានទទួលពីដំបូងនោះឡើយ ។

មាត្រា ៨
ដំណោះស្រាយវិវាទ រវាងភាគីជាប់កិច្ចសន្យា និងអ្នកវិនិយោគ នៃ ភាគីជាប់កិច្ចសន្យាម្ខាងទៀត

១- វិវាទណាមួយដែលកើតឡើងរវាងអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាង ជាមួយភាគីជាប់កិច្ចសន្យាម្ខាងទៀតពាក់ព័ន្ធទៅនឹងការវិនិយោគនៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យានោះ ត្រូវធ្វើការចរចារវាងភាគីដែលមានវិវាទនោះ ។

២- ប្រសិនបើវិវាទរវាងអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាង ជាមួយភាគីជាប់កិច្ចសន្យាម្ខាងទៀតនោះ មិនអាចដោះស្រាយបានក្នុងរយៈពេលប្រាំមួយខែ ចាប់ពីថ្ងៃដែលករណីវិវាទត្រូវបានលើកឡើង អ្នកវិនិយោគមានសិទ្ធិបញ្ជូនករណីនោះ តាមការជ្រើសរើសរបស់ខ្លួន ដើម្បីសុំការដោះស្រាយទៅ:

/ក/ តុលាការមានសមត្ថកិច្ច ឬតុលាការរដ្ឋបាលនៃភាគី ជាប់កិច្ចសន្យាដែលជាភាគីមានជំលោះ ឬ

/ខ/ មជ្ឈមណ្ឌលអន្តរជាតិទទួលបន្ទុកដោះស្រាយវិវាទវិនិយោគ (ICSID) ដែលអនុវត្តនូវបទប្បញ្ញត្តិ ផ្អែកតាមអនុសញ្ញាស្តីពីដំណោះស្រាយវិវាទវិនិយោគរវាងរដ្ឋ និងជនជាតិនៃរដ្ឋនានាដែលបានចុះហត្ថលេខានៅទីក្រុងវ៉ាស៊ីនតោន កាលពីថ្ងៃទី ១៨ ខែ មិនា ឆ្នាំ ១៩៦៥ ប្រសិនបើភាគីជាប់កិច្ចសន្យាទាំងពីរជាភាគីនៃអនុសញ្ញានេះ ឬ

/គ/ អាជ្ញាកណ្តាលតែម្នាក់ ឬតុលាការអាជ្ញាកណ្តាលអន្តរជាតិពិសេស AD HOC ដែលបានបង្កើតឡើងតាមវិធាននៃច្បាប់អាជ្ញាកណ្តាលរបស់គណៈកម្មការសហប្រជាជាតិ ស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ (UNCITRAL) ។ ភាគីមានវិវាទ អាចយល់ព្រមធ្វើការផ្លាស់ប្តូរវិធានទាំងនោះជាលាយលក្ខណ៍អក្សរ ។

៣- តុលាការអាជ្ញាកណ្តាលត្រូវសំរេចក្តីលើមូលដ្ឋានច្បាប់ ដោយយកចិត្តទុកដាក់ទៅលើប្រភពនៃច្បាប់តាមឋានានុក្រមដូចតទៅ:

- បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ និងកិច្ចព្រមព្រៀងផ្សេងទៀតដែលមានការពាក់ព័ន្ធរវាងភាគីជាប់កិច្ចសន្យា
- ច្បាប់ជាធរមាននៃភាគីជាប់កិច្ចសន្យាដែលពាក់ព័ន្ធ
- បញ្ញត្តិនៃកិច្ចព្រមព្រៀងពិសេស ពាក់ព័ន្ធដល់ការវិនិយោគ
- គោលការណ៍ទូទៅនៃច្បាប់អន្តរជាតិ ។

៤- ការសំរេចរបស់អាជ្ញាកណ្តាលគឺជាការសំរេចចុងក្រោយ ដែលភាគីមានវិវាទទាំងពីរត្រូវតែគោរព ហើយត្រូវបានអនុវត្តដោយស្របទៅតាមនីតិវិធីតុលាការក្នុងស្រុក ។

មាត្រា ៩
ការដោះស្រាយវិវាទ រវាងភាគីជាប់កិច្ចសន្យា

១- វិវាទរវាងភាគីជាប់កិច្ចសន្យាដែលទាក់ទងដល់ការបកស្រាយ ឬការអនុវត្តន៍កិច្ចព្រមព្រៀងនេះ នឹងត្រូវដោះស្រាយតាមការចរចា នៅតាមលទ្ធភាពដែលអាចធ្វើបាន ។

២- ប្រសិនបើវិវាទមិនអាចដោះស្រាយបានក្នុងរយៈពេលប្រាំមួយខែទេនោះ វិវាទត្រូវស្នើឡើងដោយភាគីជាប់កិច្ចសន្យាណាមួយ ទៅតុលាការអាជ្ញាកណ្តាលស្របតាមបញ្ញត្តិនៃមាត្រានេះ ។

៣- តុលាការអាជ្ញាកណ្តាលនោះ ត្រូវបានបង្កើតឡើងទៅតាមករណីផ្ទាល់ខ្លួនតាមបែបបទដូចតទៅ: ក្នុងរយៈពេលពីរខែនៃការទទួលបាននូវសំណើដើម្បីសុំឱ្យមានការធ្វើអាជ្ញាកណ្តាល ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវតែងតាំងសមាជិកអាជ្ញាកណ្តាលម្នាក់ ។
បន្ទាប់មកសមាជិកទាំងពីរនេះត្រូវជ្រើសរើសជនជាតិម្នាក់នៃតតិយរដ្ឋ ដែលបានការយល់ព្រមពីភាគីជាប់កិច្ចសន្យាទាំងពីរដើម្បីធ្វើជាប្រធានតុលាការអាជ្ញាកណ្តាល (ចាប់ពីពេលនេះទៅហៅថាប្រធាន) ។ ប្រធាននេះ ត្រូវបានតែងតាំងអោយហើយស្រេចក្នុងរយៈពេល បី ខែ គិតពីថ្ងៃ ដែលបានតែងតាំងសមាជិកទាំងពីររូប ។

៤- ប្រសិនបើក្នុងរយៈពេលដែលបានកំណត់ក្នុងកថាខ័ណ្ឌទី៣នៃមាត្រានេះ ការតែងតាំងមិនអាចធ្វើបាន

បាន សំណើតែងតាំងអាចស្នើទៅប្រធានតុលាការអន្តរជាតិដើម្បីសុំឱ្យធ្វើការតែងតាំងដ៏ចាំបាច់នេះ ។ ក្នុងករណី ប្រធានតុលាការនោះ ជាជនជាតិ នៃភាគីជាប់កិច្ចសន្យាណាមួយ ឬមិនអាចបំពេញមុខងារ ងារនេះបាន អនុប្រធានតុលាការត្រូវបានអញ្ជើញដើម្បីធ្វើការតែងតាំងដ៏ចាំបាច់នេះ ។ ប្រសិនបើ អនុប្រធានតុលាការនោះ ជាជនជាតិនៃភាគីជាប់កិច្ចសន្យាណាមួយ ឬមិនអាចបំពេញមុខងារនេះបានទៀត សមាជិករបស់តុលាការយុត្តិធម៌អន្តរជាតិ ដែលមានឋានៈខ្ពស់បន្ទាប់ដែលមិនមែនជាជនជាតិនៃភាគីជាប់កិច្ចសន្យាណាមួយ នឹងត្រូវបានអញ្ជើញដើម្បីទទួលការតែងតាំងដ៏ចាំបាច់នេះ ។

៥- តុលាការអាជ្ញាកណ្តាលត្រូវសំរេចក្តីទៅតាមរយៈការបោះឆ្នោតយកសំឡេងភាគច្រើន ។ការសំរេចក្តីបែបនេះភាគីវិវាទត្រូវតែគោរពតាម ។ ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវទទួលរ៉ាប់រងចេញនូវសោហ៊ុយចំណាយសំរាប់អាជ្ញាកណ្តាលរបស់ខ្លួន និងសំរាប់អ្នកតំណាងស្របច្បាប់របស់ខ្លួនក្នុងដំណើការដំណោះស្រាយវិវាទរបស់អាជ្ញាកណ្តាល ។ តម្លៃចំណាយសំរាប់ប្រធានតុលាការ និងចំណាយដែលនៅសេសសល់ទៀត ត្រូវតែជាបន្ទុកស្មើគ្នា ដែលភាគីទាំងពីរត្រូវទទួលរ៉ាប់រង ។ តុលាការអាជ្ញាកណ្តាលត្រូវកំណត់នូវ នីតិវិធីការងារសំរាប់កិច្ចដំណើរការរបស់ខ្លួន ។

មាត្រា ១០
ការអនុវត្តន៍បណ្តាទំនៀមផ្សេងៗ និងការសន្យាពិសេស

១- ប្រសិនបើនៅពេលណាដែលបញ្ហាមួយត្រូវបានគ្រប់គ្រងព្រមគ្នា ដោយកិច្ចព្រមព្រៀងនេះ និងដោយកិច្ចព្រមព្រៀងអន្តរជាតិមួយទៀត ដែលភាគីជាប់សន្យាទាំងពីរជាភាគីនោះ គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះដែលរារាំងមិនឱ្យភាគីជាប់កិច្ចសន្យាណាមួយ ឬអ្នកវិនិយោគរបស់ខ្លួនដែលបានធ្វើការវិនិយោគនៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតក្នុងការទទួលបាននូវអត្ថប្រយោជន៍នៃវិធានណាមួយដែលមានភាពអនុគ្រោះសំរាប់ករណីរបស់គេនោះឡើយ ។

២- ប្រសិនបើប្រព្រឹត្តកម្មដែលបានយល់ព្រមផ្តល់ដោយភាគីជាប់កិច្ចសន្យាម្ខាងជូនអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ដោយអនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួន ឬបទប្បញ្ញត្តិពិសេសផ្សេងទៀតនៃកិច្ចសន្យា ដែលមានភាពអនុគ្រោះជាងអ្វីដែលបានយល់ព្រមដោយកិច្ចព្រមព្រៀងនេះ ភាពអនុគ្រោះដែលប្រសើរជាងនោះ ត្រូវតែបានទទួលការយល់ព្រមផងដែរ ។

មាត្រាទី ១១
អត្ថប្រយោជន៍នៃសន្តិសុខពិសេស

១- មិនមានអ្វីក្នុងកិច្ចព្រមព្រៀងនេះត្រូវបានបកស្រាយដើម្បីរារាំងភាគីជាប់កិច្ចសន្យាណាមួយ ក្នុងការប្រកាន់យកនូវសកម្មភាព ដែលគេពិចារណាថា ចាំបាច់ត្រូវប្រកាន់យកសំរាប់ការពារផលប្រយោជន៍នៃសន្តិសុខពិសេសរបស់គេនោះឡើយៈ

/ក/ ទាក់ទងទៅនឹងបទល្មើសឧក្រិដ្ឋ ឬព្រហ្មទណ្ឌ

/ខ/ ទាក់ទងនឹងការរត់ពន្ធអាវុធ គ្រាប់រំសេវ និងសម្ភារៈបំរើសង្គ្រាម និងការធ្វើអាជីវកម្មលើទំនិញ សម្ភារៈបរិក្ខារ សេវាកម្ម និងបច្ចេកវិទ្យា ដទៃទៀត ដែលបានអនុវត្តដោយផ្ទាល់ ឬ ដោយប្រយោលក្នុងគោលបំណងធ្វើការផ្គត់ផ្គង់ឱ្យកំលាំងយោធា ឬការបង្កើតសន្តិសុខដទៃទៀត ។

/គ/ មានទំនាក់ទំនងអន្តរជាតិក្នុងពេលមានសង្គ្រាម ឬករណីប្រកាសអាសន្នដទៃទៀត ឬ

/ឃ/ទាក់ទងទៅនឹងការអនុវត្តគោលនយោបាយរបស់ជាតិ ឬកិច្ចព្រមព្រៀងអន្តរជាតិ ក្នុងការគោរពនូវគោលការណ៍មិនសាយភាយអាវុធនុយក្លេអ៊ែរ ឬ ឧបករណ៍បំផ្ទុះនុយក្លេអ៊ែរដទៃទៀត ឬ

/ង/ដោយយោលទៅតាមកាតព្វកិច្ចនៃធម្មនុញ្ញសហប្រជាជាតិ ស្តីពីការថែរក្សានូវសន្តិភាព និងសន្តិសុខអន្តរជាតិ ។

២- អត្ថប្រយោជន៍នៃសន្តិសុខពិសេសរបស់ភាគីជាប់កិច្ចសន្យា អាចរួមបញ្ចូលផងដែរនូវអត្ថប្រយោជន៍ដែលកើតមានមកពីភាពជាសមាជិករបស់ខ្លួននៅក្នុង សហភាព គយ សេដ្ឋកិច្ច ឬហិរញ្ញវត្ថុ ទីផ្សាររួម ឬតំបន់ពាណិជ្ជកម្មសេរី ។

មាត្រាទី ១២
ទំហំវិសាលភាពគ្របដណ្តប់ នៃ កិច្ចព្រមព្រៀង

បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ នឹងអនុវត្ត ចំពោះការវិនិយោគនាពេលអនាគត ដែលធ្វើឡើងដោយអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងនៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត និងការវិនិយោគមានស្រាប់ដែលកំពុងដំណើរការស្របតាមច្បាប់នៃភាគីជាប់កិច្ចសន្យា នៅថ្ងៃដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន ។ ទោះបីជាយ៉ាងនេះក៏ដោយ បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ នឹងមិនអនុវត្តន៍ចំពោះការតវ៉ាទាមទារដែលកើតមាន ឬ ការតវ៉ាដែលបានដោះស្រាយរួច មុនការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះឡើយ ។

មាត្រា ១៣
ការចូលជាធរមាន ថេរវេលា និងការបញ្ចប់

១- ភាគីជាប់កិច្ចសន្យាម្ខាង ត្រូវជូនដំណឹងទៅភាគីជាប់កិច្ចសន្យាម្ខាងទៀត នូវការបំពេញរួចរាល់ហើយ អំពីនីតិវិធីដែលតម្រូវដោយច្បាប់របស់ខ្លួន ដើម្បីដាក់ឱ្យកិច្ចព្រមព្រៀងនេះចូលជាធរមាន ។ កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមាន ក្រោយរយៈពេល៣០ថ្ងៃ បន្ទាប់ពីការជូនដំណឹងជាលើកទីពីរ ។

២- កិច្ចព្រមព្រៀងនេះ មានសុពលភាពរយៈពេលដប់ឆ្នាំ ។ បន្ទាប់ពីរយៈនោះ កិច្ចព្រមព្រៀងនៅមានសុពលភាពរហូតដល់ផុតកំណត់រយៈពេលដប់ពីរខែ គិតចាប់ពីថ្ងៃដែលភាគីជាប់កិច្ចសន្យាម្ខាងបានជូនដំណឹងទៅភាគីជាប់កិច្ចសន្យាម្ខាងទៀត ជាលាយលក្ខណ៍អក្សរអំពីគោលបំណងរបស់ខ្លួនក្នុងការបញ្ចប់កិច្ចព្រមព្រៀង ។

៣- ចំពោះការវិនិយោគដែលបានធ្វើមុនការបញ្ចប់សុពលភាពនៃកិច្ចព្រមព្រៀងនេះ បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ នឹងបន្តមានសុពលភាពរយៈពេលដប់ឆ្នាំ បន្ទាប់ពីថ្ងៃបញ្ចប់សុពលភាព ។

ដើម្បីជាសាក្សីនៃកិច្ចព្រមព្រៀងនេះ អ្នកតំណាងស្របច្បាប់ ដែលបានទទួលសិទ្ធិអំណាចគ្រប់គ្រាន់ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។

កិច្ចព្រមព្រៀងនេះធ្វើនៅ ...ភ្នំពេញ............ ថ្ងៃទី 12...[illegible]...ឆ្នាំ 2008 ជាភាសាខ្មែរ ភាសាឆែក ភាសាអង់គ្លេស អត្ថបទទាំងអស់នេះមានតំលៃគតិយុត្តិស្មើៗគ្នា ។ ក្នុងករណីមានការបកស្រាយមិនស្របគ្នានោះ អត្ថបទជាភាសាអង់គ្លេស ត្រូវបានយកមកធ្វើជាសំអាង ។

តំណាងរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា	តំណាងរដ្ឋាភិបាល នៃសាធារណរដ្ឋឆែក
....	Ivan Hotek

AGREEMENT

BETWEEN THE GOVERNMENT OF THE KINGDOM OF CAMBODIA AND THE GOVERNMENT OF THE CZECH REPUBLIC FOR THE PROMOTION AND RECIPROCAL PROTECTION OF INVESTMENTS

The Government of the Kingdom of Cambodia and Government of the Czech Republic (hereinafter referred to as the "Contracting Parties"),

Desiring to develop economic co-operation to the mutual benefit of both States,

